ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

សាលក្រមរដ្ឋប្បវេណីលេខ:១២ (ក)

ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តតាកែវ**

-បានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ និងប្រកាសសាលក្រមនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០២៤ ដោយមានសមាសភាពចូលរួម៖

**ចៅក្រម**

លោក [redacted] អនុប្រធាននិងជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ដើម្បីទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ:២៤០ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២៣ដែលមានកម្មវត្ថុ:សុំអោយតុលាការចេញសាលក្រមដូចខាងក្រោម៖

១-ទាមទារប្រាក់ដើមចំនួន ២៩.២០០ $

២-ទាមទារការប្រាក់១៨% ក្នុង១ឆ្នាំលើប្រាក់២៩.២០០$ ចាប់ពីថ្ងៃទី១១.០១.២០២១

៣-ទាមទារសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ផលប្រយោជន៍និងថ្លៃចំណាយសេវាផ្លូវច្បាប់ ចំនួន២០.០០០$ ។

៤-សុំប្រកាសអនុវត្តសាលក្រមជាបណ្ដោះអាសន្ន ត្រង់ចំណុចទី១ខាងលើ ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

-ដើមចោទឈ្មោះ[redacted]តិចម៉េង ភេទ ប្រុស អាយុ ៥៧ ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ[redacted] គីមចាយ ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted]។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិការពារសិទ្ធិអោយដើមចោទឈ្មោះ [redacted] និងឈ្មោះ[redacted]។

-សហចុងចម្លើយ ៖

១-ឈ្មោះ [redacted]ភេទស្រី អាយុ ៤៦ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅ[redacted]ឪពុកឈ្មោះ[redacted] អ៊ីម (រស់) ម្ដាយឈ្មោះ[redacted]រុន (រស់) ប្ដីឈ្មោះ[redacted]ណុំ មានកូន ០២ នាក់

២-ឈ្មោះ [redacted] រុន ភេទស្រី អាយុ ៧២ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ឪពុកឈ្មោះ [redacted] អៀង ( ស្លាប់ ) ម្ដាយឈ្មោះ [redacted]សំ ( ស្លាប់ ) ប្រពន្ធឈ្មោះ[redacted] អ៊ីម មានកូន ០៨ នាក់ ។

-លោក[redacted] និងលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិអោយសហចុងចម្លើយឈ្មោះ [redacted]ទ៉ាភ័ន់ និងឈ្មោះ[redacted] រុន

**អង្គហេតុ និងចំណុចវិវាទ៖**



Scanned with CamScanner

១-សាលក្រមដែលទាមទារដោយគូភាគី ៖

១-១-ការទាមទារដោយដើមចោទ:

ក-ទាមទារប្រាក់ដើមចំនួន ២៩.២០០ $

ខ-ទាមទារការប្រាក់១៨% ក្នុង១ឆ្នាំលើប្រាក់២៩.២០០$ ចាប់ពីថ្ងៃទី១១.០១.២០២១

គ-ទាមទារសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ផលប្រយោជន៍និងថ្លៃចំណាយសេវាផ្លូវច្បាប់ចំនួន២០.០០០$ ។

ឃ-សុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ខាងលើ ។

ង-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

១-២-ការទាមទារដោយសហចុងចម្លើយ:

-សុំឱ្យតុលាការច្រានពាក្យបណ្តឹងរបស់ដើមចោទចោល

២-ការពន្យល់ត្រួសៗអំពីរឿងក្តី:

-កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] វុន បានមកខ្ចីប្រាក់ពីខ្លួនចំនួន៤២.២០០$ ពីដើមចោទឈ្មោះ[redacted] តិចម៉េង និងប្រពន្ធឈ្មោះ[redacted] គីមចាយ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ។ ក្រោយមកចុងចម្លើយសងប្រាក់បានចំនួន១៣.០០០$ នៅខ្វះប្រាក់ចំនួន២៩.២០០$ ទៀតចុងចម្លើយពុំព្រមសង ក៏បានទៅដោះស្រាយគ្នានៅសាលាឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] អ៊ឹម បានទទួលស្គាល់ប្រាក់ជំពាក់ចំនួន២៩.២០០$ ។ លុះមកដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ក៏បានទៅដោះស្រាយគ្នានៅសាលាឃុំម្តងទៀត ពេលនោះឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ខ្ញុំចំនួន៧.០០០$(ប្រាំពីរពាន់)ដុល្លារ ពុំមានប្រាក់សង ។ សហចុងចម្លើយថ្លែងការណ៍បានសងប្រាក់រួចរាល់អស់ហើយ ប៉ុន្តែសហដើមចោទថ្លែងការការណ៍ថាពុំដែលបានទទួលការសងប្រាក់របស់សហចុងចម្លើយទេ។

៣-អង្គហេតុដែលមានវិវាទ:

-ដើមចោទទាមទារប្រាក់ជំពាក់ចំនួន២៩.២០០$ សហចុងចម្លើយបានឆ្លើយថាបានសងរួច ។

៤-អង្គហេតុដែលគ្មានវិវាទ:គ្មាន

៥-សេចក្តីថ្លែងការណ៍របស់គូភាគី:

ក-សេចក្តីថ្លែងការណ៍របស់ដើមចោទ

-ដើមចោទឈ្មោះ [redacted] តិចម៉េង និងប្រពន្ធឈ្មោះ[redacted] គីមចាយ បានចូលមកធ្វើសេចក្តីថ្លែងការណ៍ដូចគ្នាថា យើងខ្ញុំទាមទារប្រាក់ដើមចំនួន២៩.២០០$ ការប្រាក់១៨%ក្នុង១ឆ្នាំ និងសំណងការខាតបង់ពេលវេលា និងសេវាផ្សេងៗសរុបចំនួន២០.០០០$ និងសុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទាមទារប្រាក់ដើមចំនួន២៩.២០០$ ដោយសំអាងហេតុថា កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] វុន បានមកខ្ចីប្រាក់ពីខ្លួនចំនួន៤២.២០០$ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ។ ក្រោយមកសហចុងចម្លើយសងប្រាក់បានចំនួន១៣.០០០$ នៅខ្វះប្រាក់ចំនួន២៩.២០០$ ទៀតសហចុងចម្លើយពុំព្រមសង ក៏បានទៅដោះស្រាយគ្នានៅសាលាឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ពេលនោះឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] អ៊ឹម ចូលរួម បានទទួលស្គាល់ប្រាក់ជំពាក់ចំនួន២៩.២០០$ ប៉ុន្តែពួកគាត់ពុំបានសន្យាសងប្រាក់នៅពេលណានោះទេ ។ ក្នុងពេលដោះស្រាយនោះមានលោកមេឃុំឈ្មោះ



Scanned with CamScanner

[redacted]បុត្រ ព្រមទាំងមានគណកម្មការឃុំជាច្រើននាក់ចូលរួម ដោយបានធ្វើកំណត់ហេតុត្រឹមត្រូវ ។ លុះមកដល់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ក៏បានទៅដោះស្រាយគ្នានៅសាលាឃុំម្តងទៀត ពេលនោះឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ខ្ញុំចំនួន៧.០០០$(ប្រាំពីរពាន់)ដុល្លារ និងឆ្លើយថាបានសងរួច ប៉ុន្តែយើងខ្ញុំពុំដែលបានទទួលការសងនេះឡើយ ។ ដូច្នេះនៅក្នុងរឿងនេះយើងខ្ញុំនៅតែប្តឹងទាមទារដូចក្នុងកម្មវត្ថុខាងលើ ។

ខ-សេចក្តីថ្លែងការណ៍របស់សហចុងចម្លើយ

-ចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] រុន បានចូលមកថ្លែងការណ៍ដូចគ្នាថា យើងខ្ញុំពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន៤២.២០០$ (បួនម៉ឺនពីរពាន់ពីររយ)ដុល្លារ ប្រាកដមែន ។ ក្រោយមកយើងបានខ្ចីប្រាក់ពីឈ្មោះនៅ ប្រពន្ធឈ្មោះង៉ែត ចំនួន៨០.០០០$ យកមកសងដើមចោទចំនួន៦០.០០០$ នៅខ្វះប្រាក់ចំនួន១០.០០០$ ទើបគាត់សុខចិត្តប្រគល់ប្លង់ដីទាំងបួនមកវិញ ។ ក្រោយមកខ្លួនមានប្រាក់ចំនួន៨.០០០$ សងទៅដើមចោទបានដកយកប្លង់មកវិញចំនួន០២ នៅខ្វះ០២ប្លង់ទៀត ។ រាល់ការសងប្រាក់ពុំបានធ្វើលិខិតស្នាមទេ ។

-លោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីរបស់ខ្ញុំបាទបានអះអាងថា សហចុងចម្លើយនៅជំពាក់ប្រាក់ខ្លួនចំនួន២៩.២០០$ ដោយសំអាងហេតុថា សហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន៤២.២០០$ សងបានចំនួន១៣.០០០$ នៅខ្វះចំនួន២៩.២០០$ ពុំព្រមសងក៏បានទៅដោះស្រាយគ្នានៅសាលាឃុំខ្នារ ស្រុកសំរោង ខេត្តតាកែវ ចំនួន០២លើក ដោយមានលោកកង [redacted] ជាប្រធានគណកម្មការដោះស្រាយ និងលោកស្រី[redacted]មុំ ជំទប់ទី១ ចូលរួមដោះស្រាយផ្ទាល់ ។ ដោះស្រាយលើកទី១លោក[redacted] ថាន់ បញ្ជាក់ថាឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់កូនក្តីខ្ញុំចំនួន២៩.២០០$ មែន ប៉ុន្តែពុំមានលទ្ធភាពសងទេ ។ ចំណែកលោកស្រី [redacted] មុំ ឆ្លើយថាពេលនោះខ្លួនជាជំទប់ទី១ បានចូលដោះស្រាយបានឮសំដីឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ដើមចោទចំនួន២៩.២០០$ ដែរ ។ លើកទី២បានធ្វើកំណត់ហេតុត្រឹមត្រូវ ឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ដើមចោទចំនួន៧.០០០$ នៅពេលនេះគាត់ឆ្លើយថាសងរួចរាល់អស់ហើយ នេះជាចម្លើយ ឆ្លើយទៅមុខទៅក្រោយ ព្រោះតាមកំណត់ហេតុលើកទី១ ទី២ នៅចំពោះមុខអាជ្ញាធរឃុំ ចុងចម្លើយពុំបានលើកឡើងពីការសងប្រាក់ចំនួន៦០.០០០$ ឡើយ ។ ប៉ុន្តែពេលនេះឆ្លើយថាបានសងចំនួន៦០.០០០$ ចម្លើយនេះធ្វើអោយតុលាការមានការភាន់ច្រឡំ សម្រេចសេចក្តីខុសពីការពិត ។ ហេតុនេះសុំអោយតុលាការសម្រេចទៅតាមច្បាប់ ។

-លោក [redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍ថា ទាក់ទងចំនួនទឹកប្រាក់ដែលកូនក្តីរបស់ខ្ញុំជំពាក់ចំនួន២៩.២០០$ បានសងនៅឆ្នាំ២០១៨ ដោយនៅក្នុងនោះ កូនក្តីរបស់ខ្ញុំបានទៅខ្ចីប្រាក់ពីឈ្មោះនៅ ប្រពន្ធឈ្មោះង៉ែត ដើម្បីយកមកសងផ្តាច់ជាមួយដើមចោទ ។ ចំពោះការដោះស្រាយគ្នានៅសាលាឃុំលើកទី១ ទី២ កូនក្តីរបស់ខ្ញុំបានចូលរួមមែន ប៉ុន្តែកូនក្តីរបស់ខ្ញុំពុំបានទទួលស្គាល់ថាបានជំពាក់ប្រាក់ដើមចោទទៀតទេ ។ ជាពិសេសការដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន(សាលាឃុំ) ពុំបានប្រគល់កំណត់ហេតុអោយសាមីខ្លួនពិនិត្យ និងផ្តិតមេដៃទេ ជាពិសេសលើកទី១ ជាគោលការណ៍ដោះស្រាយរឿងក្តីរដ្ឋប្បវេណីត្រូវប្រគល់អោយសាម៉ីខ្លួន០១ច្បាប់ ។ជាក់ស្តែងដូចកូនក្តីរបស់ខ្ញុំលើកឡើងថា ការដោះស្រាយលើកទី១កូនក្តីរបស់ខ្ញុំពុំទទួលបានឯកសារជាកំណត់ហេតុទេ ឯដើមចោទមានឯកសារនេះ ។ ហេតុនេះសូមលោកចៅក្រមមេត្តាពិនិត្យពិចារណា ជាពិសេសអង្គហេតុ៦០.០០០$ ជាអង្គហេតុពិតប្រាកដ ព្រោះគាត់ហ៊ានដាក់ធូបមកស្បថជូន ទោះជាកូនក្តីរបស់ខ្ញុំគ្មានឯកសារមកបង្ហាញ ក៏បង្ហាញឆន្ទៈជូនតុលាការដែរ ។ សំណូមពរ សុំអោយតុលាការច្រានចោលពាក្យបណ្តឹងរបស់ដើមចោទចោលជាអាសារបង់ ។



Scanned with CamScanner

-លោក[redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ថ្លែងការណ៍ថា ការសងប្រាក់ចំនួន ៦០.០០០$ អោយមកកូនក្តីរបស់ខ្ញុំ តើមានឯកសារឬទេ ? ពេលជំពាក់ប្រាក់ចំនួន៤២.២០០$ មានកិច្ចសន្យា ។ សាក្សីទាំងពីរនាក់ដែលជាអាជ្ញាធរ គាត់លើកឡើង ជាអាជ្ញាកណ្តាល ពុំបានកាន់ជើងភាគីណាឡើយ ។ ហេតុនេះ សុំអោយតុលាការច្រានចោលការលើកឡើងរបស់ចុងចម្លើយ និងមេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ។

**៦-ការពិនិត្យភស្តុតាងមាន:**

**ក-ភស្តុតាងជាសាក្សី**

-សាក្សីឈ្មោះ[redacted] ថាន់ ភេទប្រុស អាយុ៦៨ឆ្នាំ ជាក្រុមប្រឹក្សាឃុំខ្វាវ បានចូលមកឆ្លើយថា កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ឈ្មោះ[redacted] ម៉ារ៉ាល់ បានមកប្តឹងសុំដកប្លង់ដីលេខ:២៤០ទៅវិញ ក៏បានដោះស្រាយគ្នានៅ សាលាឃុំខ្វាវ ពេលនោះឈ្មោះ[redacted] ម៉ារ៉ាល់ បានលើកឡើងថាបានខ្ចីប្រាក់ពីឈ្មោះអៀ គីមចាយ ចំនួន៣៦.០០០$ បានសងប្រាក់គ្រប់ចំនួនហើយ ។ ពេលនោះឈ្មោះ[redacted] ម៉ារ៉ាន់ , [redacted] រុន និងឈ្មោះ[redacted] អ៊ឹម បានឆ្លើយថាពួកខ្លួន បានខ្ចីប្រាក់ពីឈ្មោះ[redacted] គីមចាយ ចំនួន៤២.២០០$ បានសងមួយចំនួននៅជំពាក់ចំនួន២៩.២២៨$ មិនទទួល សងទៀតទេ ពេលនោះខ្ញុំជាប្រធានអង្គប្រជុំបានកត់ត្រាក្នុងសៀវភៅច្បាស់លាស់ ។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២២ បានដោះស្រាយគ្នាម្តងទៀត ឈ្មោះ[redacted] គីមចាយ បានលើកឡើងថា ឈ្មោះ[redacted] ម៉ារ៉ា នៅជំពាក់ប្រាក់ខ្លួន ចំនួន៧៧.៨៦០$ ឈ្មោះ[redacted] ម៉ារ៉ាន់ នៅជំពាក់ប្រាក់ចំនួន២៩.២០០$ ប៉ុន្តែឈ្មោះអ៊ុ ម៉ារ៉ា ឆ្លើយថានៅជំពាក់ប្រាក់ ចំនួន៥៣.០០០$ [redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ដើមចោទចំនួន៧.០០០$ តែអត់មានអីសងបន្ត ។ ឈ្មោះ[redacted] ម៉ារ៉ា ឆ្លើយថាប្រាក់៥៣.០០០$ បានសងរួចហើយ ។ ឈ្មោះ[redacted] គីមចាយ បានឆ្លើយថា មិនបានសងទេ តើសង នៅពេលណា ។

-សាក្សីឈ្មោះ[redacted] មុំ ភេទស្រី អាយុ៥៣ឆ្នាំ ជាមេឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ បានចូលមកឆ្លើយថា កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ នាងខ្ញុំក៏បានចូលរួមដោះស្រាយរឿងក្តីរបស់ឈ្មោះ[redacted] គីមចាយ និង ឈ្មោះ[redacted] ម៉ារ៉ាន់ , [redacted] រុន និងឈ្មោះ[redacted] អ៊ឹម ពេលនោះឈ្មោះ[redacted] ម៉ារ៉ាន់ , [redacted] រុន និងឈ្មោះ[redacted] អ៊ឹម បានឆ្លើយ ថាពួកខ្លួនបានខ្ចីប្រាក់ពីឈ្មោះ[redacted] គីមចាយ ចំនួន៤២.២០០$ បានសងមួយចំនួននៅជំពាក់ចំនួន២៩.២២៨$ ។ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ បានដោះស្រាយគ្នាម្តងទៀត ឈ្មោះ[redacted] គីមចាយ បានលើកឡើងថា ឈ្មោះ[redacted] ម៉ារ៉ា នៅជំពាក់ប្រាក់ខ្លួនចំនួន៧៧.៨៦០$ ឈ្មោះ[redacted] ម៉ារ៉ាន់ នៅជំពាក់ប្រាក់ចំនួន២៩.២០០$ ប៉ុន្តែឈ្មោះ[redacted] ម៉ារ៉ា ឆ្លើយថានៅជំពាក់ប្រាក់ចំនួន៥៣.០០០$ ឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់ដើមចោទចំនួន៧.០០០$ អត់ មានអីសងទេ ។ ឈ្មោះ[redacted] ម៉ារ៉ា ឆ្លើយថាប្រាក់៥៣.០០០$ បានសងរួចហើយ ។ ឈ្មោះ[redacted] គីមចាយ បានឆ្លើយ ថា មិនបានសងទេ តើសងនៅពេលណា ។

-សាក្សីឈ្មោះ[redacted] អ៊ឹម ភេទប្រុស ត្រូវជាប្តីរបស់ឈ្មោះ[redacted] រុន បានចូលមកឆ្លើយថាកូនខ្ញុំឈ្មោះ[redacted] ម៉ារ៉ាន់ ពិតជាបានខ្ចីប្រាក់ពីឈ្មោះ[redacted] គីមចាយ ចំនួន៤២.២០០$ ប្រាកដមែន ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ក្រោយ មកកូនរបស់ខ្ញុំបានសងរួចរាល់អស់ហើយ ប៉ុន្តែពុំបានធ្វើលិខិតស្នាមអ្វីទេ ។

**ខ-ភស្តុតាងជាលិខិតស្នាម**

-ពាក្យបណ្តឹង ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ របស់ឈ្មោះ[redacted] តិចម៉េង និងឈ្មោះ[redacted] គីមចាយ

-កិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:២១០៧០៥១៨-០២១៣ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ:២១០៧០៥១៨-០២១៧ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩



Scanned with CamScanner

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ២១០៧០៩១៨-០២១៨ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩

-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខៈ២១០៧០៩១៨-០២៤០ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩

-ពាក្យសុំជូនពិនិត្យភស្តុតាងជាឯកសារ និងសាក្សី

-កិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧

-កិច្ចសន្យាលក់ផ្តាច់ ឈ្មោះ[redacted]ម៉ារ៉ា និងឈ្មោះ[redacted]អ៊ីម បានលក់ដីដែលមានក្បាលដីលេខៈ៣៧២,២១៣, ២១៨,២០៩ អោយឈ្មោះ[redacted]តិចម៉េង និងឈ្មោះ[redacted]គីមចាយ

-កិច្ចសន្យាចងការប្រាក់ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦

-កិច្ចសន្យាលក់ផ្តាច់ ឈ្មោះ[redacted]អ៊ីម និងឈ្មោះ[redacted] រុន បានលក់ដីដែលមានក្បាលដីលេខៈ២៤០,៤៦៨, ១១៥ អោយឈ្មោះ[redacted] តិចម៉េង និងឈ្មោះ[redacted] គីមចាយ

-កំណត់ហេតុចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ នៅសាលាឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ

-កំណត់ត្រាដៃ របស់លោក[redacted] ថាន់ ក្រុមប្រឹក្សាឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ

-កំណត់ហេតុចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ នៅសាលាឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ

## សំអាងហេតុ

១-បណ្តឹងរបស់ដើមចោទឈ្មោះ [redacted] តិចម៉េង និងឈ្មោះ[redacted] គីមចាយ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០២៣ មានលក្ខណៈត្រឹមត្រូវតាមទំរង់និងតតិច្បាប់ តុលាការគប្បីទទួលមកចាត់ការបាន ។

២-ដើមចោទឈ្មោះ[redacted] តិចម៉េង និងឈ្មោះ[redacted] គីមចាយ ប្តឹងសុំទាមទារប្រាក់ដើមចំនួន២៩.២០០$ ការប្រាក់១៨%ក្នុង១ឆ្នាំ ទាមទារសំណងការខាតបង់ពេលវេលា និងសេវាផ្សេងៗសរុបចំនួន២០.០០០$ ហើយ សុំប្រកាសអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទាមទារប្រាក់ដើមចំនួន២៩.២០០$ និងអោយសហចុង ចម្លើយទទួលរ៉ាប់រងលើប្រាក់ប្រដាប់ក្តី ដោយសំអាងហេតុថា សហចុងចម្លើយបានខ្ចីប្រាក់ចំនួន៤២.២០០$ ក្រោយមកសហចុងចម្លើយសងបានចំនួន១៣.០០០$ នៅខ្វះចំនួន២៩.២០០$ ពុំព្រមសង ។ ការលើកឡើងនេះ មានលក្ខណៈសមហេតុផល តុលាការអាចទទួលយកមកពិចារណាបាន ។

៣-នៅតំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ក៏ដូចជានៅនីតិវិធីទាញ ហេតុផលដោយផ្ទាល់មាត់សហដើមចោទ នៅតែទាមទារប្រាក់ជំពាក់ចំនួន២៩.២០០$ ដោយសំអាងហេតុថា សហចុងចម្លើយបានខ្ចីប្រាក់ចំនួន៤២.២០០$ បានធ្វើកិច្ចសន្យាត្រឹមត្រូវ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ។ ក្រោយមកសហចុងចម្លើយសងបានចំនួន១៣.០០០$នៅខ្វះចំនួន២៩.២០០$ ចំណែកសហចុងចម្លើយលើក ឡើងថា ពិតជាបានខ្ចីប្រាក់ពីដើមចោទចំនួន៤២.២០០$ប្រាកដមែន ក្រោយមកបានសងរួចរាល់អស់ហើយ ប៉ុន្តែពុំបានធ្វើលិខិតស្នាមអ្វីទេ ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

៤-នៅតំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ក៏ដូចជានៅនីតិវិធីទាញហេតុ ផលដោយផ្ទាល់មាត់ សហចុងចម្លើយបានលើកឡើងថា បានខ្ចីប្រាក់ពីសហដើមចោទចំនួន៤២.២០០$ប្រាកដ មែន ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ។ ក្រោយមកយើងបានទៅខ្ចីប្រាក់ពីឈ្មោះនៅ ប្រពន្ធឈ្មោះង៉ែត ចំនួន ៨០.០០០$ យកមកសងដើមចោទចំនួន៦០.០០០$ បន្ទាប់មកសងបន្ថែមចំនួន៨.០០០$ រួចគ្នាអស់ហើយ។ប៉ុន្តែ ពុំបានធ្វើលិខិតស្នាមអ្វីទេ ។ សហដើមចោទលើកឡើងថាធ្លាប់បានទទួលការសងប្រាក់ចំនួន១៣.០០០$ របស់



Scanned with CamScanner

សហចុងចម្លើយ ក្រៅពីនោះពុំដែលបានទទួលឡើយ ទើបមានការដោះស្រាយគ្នានៅសាលាឃុំខ្នារកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចុងចម្លើយទទួលស្គាល់នៅជំពាក់ចំនួន២៩.២០០$ ។ តុលាការគប្បីពិនិត្យពិចារណា និងសម្រេច ផ្អែកលើភស្តុតាងដែលបានដាក់ជូនតុលាការ ។

៥-តាមសេចក្តីថ្លែងការណ៍របស់សហចុងចម្លើយថា បានខ្ចីប្រាក់ដើមចោទចំនួន៤២.២០០$ បានធ្វើកិច្ចសន្យាចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ បានសងប្រាក់គ្រប់ចំនួននៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ ប៉ុន្តែពុំបានធ្វើលិខិតស្នាមទេ ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

៦-តាមចម្លើយសាក្សីបំភ្លឺឈ្មោះ[redacted] ថាន់ និងឈ្មោះ[redacted] មុំ មានខ្លឹមសារប្រហាក់ប្រហែលគ្នាថាខ្លួនជាជំទប់ទី១ ជាក្រុមប្រឹក្សាឃុំខ្នារ បានទទួលដោះស្រាយរឿងទាមទារប្រាក់របស់ដើមចោទឈ្មោះ[redacted] តិចម៉េង , [redacted] គីមចាយ និងចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ ,[redacted] រុន [redacted] អ៊ឹម ចំនួន០២លើកនៅសាលាឃុំខ្នារ ។ លើកទី១ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ [redacted] អ៊ឹម បានឆ្លើយថានៅជំពាក់ប្រាក់ដើមចោទចំនួន២៩.២២៨$ មិនទទួលសងទៀតទេ ។ លើកទី២នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ចុងចម្លើយបានលើកឡើងថានៅជំពាក់ប្រាក់ដើមចោទចំនួន៧.០០០$ តែអត់មានអីសងបន្ត ដើមចោទឈ្មោះ[redacted] តិចម៉េង និងឈ្មោះ[redacted] គីមចាយ បានឆ្លើយថាមិនបានសងទេ តើសងនៅពេលណា ។ តុលាការគប្បីពិនិត្យពិចារណា និងសម្រេចតាមសភាពជាក់ស្តែង ។

៧-តាមចម្លើយសាក្សីឈ្មោះ[redacted] អ៊ឹម ថា កូនខ្ញុំឈ្មោះ[redacted] ម៉ារ៉ាន់ ពិតជាបានខ្ចីប្រាក់ពីឈ្មោះ[redacted] គីមចាយ ចំនួន៤២.២០០$ ប្រាកដមែន ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ក្រោយមកកូនរបស់ខ្ញុំបានសងរួចរាល់អស់ហើយ ប៉ុន្តែពុំបានធ្វើលិខិតស្នាមអ្វីទេ ។ ចម្លើយនេះមានភាពស៊ីសង្វាក់គ្នាជាមួយចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ និង[redacted] រុន ត្រូវជាកូន និងប្រពន្ធរបស់សាក្សី ។ គប្បីតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

៨-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិអោយដើមចោទថាសុំឱ្យតុលាការសម្រេចៈ បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់មកកូនក្តីរបស់ខ្ញុំ មានប្រាក់ដើមចំនួន២៩.២០០$ ការប្រាក់១៨%ក្នុង១ឆ្នាំ គិតពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ទាមទារសំណងជំងឺចិត្ត ការខាតបង់ពេលវេលា ផលប្រយោជន៍ និងថ្លៃសេវាផ្លូវច្បាប់សរុបចំនួន២០.០០០$ និងសុំប្រកាសអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ខាងលើ ដោយសំអាងហេតុថា សហចុងចម្លើយបានខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន៤២.២០០$ សងជាបន្តបន្ទាប់រហូតមកដល់ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១បានចំនួន១៣.០០០$នៅខ្វះប្រាក់ចំនួន២៩.២០០$ ពុំព្រមសងក៏បានទៅដោះស្រាយគ្នានៅសាលាឃុំខ្នារ ចំនួន០២លើក ដោយមានលោក[redacted] ថាន់ ជាប្រធានគណកម្មការដោះស្រាយ និងលោកស្រី[redacted] មុំ ជំទប់ទី១ ចូលរួមដោះស្រាយផ្ទាល់ ។ ដោះស្រាយលើកទី១ លោក[redacted] ថាន់ និងលោកស្រី [redacted] មុំ បញ្ជាក់ថាឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់កូនក្តីខ្ញុំចំនួន២៩.២០០$ មែន ប៉ុន្តែពុំមានលទ្ធភាពសងទេ ។ លើកទី២ ឈ្មោះ[redacted] ម៉ារ៉ាន់ ឆ្លើយថានៅជំពាក់ប្រាក់កូនក្តីខ្ញុំចំនួន៧.០០០$ ហើយនៅពេលនេះគាត់ឆ្លើយថាបានសងរួចរាល់អស់ហើយ ។ តាមកំណត់ហេតុលើកទី១ ទី២ នៅចំពោះមុខអាជ្ញាធរឃុំ សហចុងចម្លើយពុំបានលើកឡើងពីការសងប្រាក់ចំនួន៦០.០០០$ ឡើយ ។ ប៉ុន្តែពេលនេះឆ្លើយថាបានសងចំនួន៦០.០០០$ តើសងនៅពេលណា មានឯកសារឬទេ ? ។ គប្បីតុលាការពិនិត្យពិចារណា ដោយផ្អែកលើភស្តុតាង និងសម្រេចតាមច្បាប់ ។

៩-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយថាទាក់ទងចំនួនទឹកប្រាក់ដែលកូនក្តីរបស់ខ្ញុំជំពាក់ចំនួន២៩.២០០$ បានសងនៅឆ្នាំ២០១៨ ដោយនៅក្នុងនោះ កូនក្តីរបស់ខ្ញុំបានទៅខ្ចី



Scanned with CamScanner

ប្រាក់ពីឈ្មោះនៅ ប្រពន្ធឈ្មោះង៉ែត ដើម្បីយកមកសងផ្ដាច់ជាមួយដើមចោទ ។ ចំពោះការដោះស្រាយគ្នានៅសាលាឃុំលើកទី១ ទី២ កូនក្ដីរបស់ខ្ញុំបានចូលរួមមែន ប៉ុន្តែកូនក្ដីរបស់ខ្ញុំពុំបានទទួលស្គាល់ថាបានជំពាក់ប្រាក់ដើមចោទទៀតទេ ។ ជាពិសេសការដោះស្រាយជាមួយអាជ្ញាធរមូលដ្ឋាន(សាលាឃុំ) ពុំបានប្រគល់កំណត់ហេតុអោយសាម៉ីខ្លួនពិនិត្យ និងផ្ដិតមេដៃទេ ជាពិសេសលើកទី១ ជាគោលការណ៍ដោះស្រាយរឿងក្ដីរដ្ឋប្បវេណីត្រូវប្រគល់អោយសាម៉ីខ្លួន០១ច្បាប់ ។ ហេតុនេះសូមលោកចៅក្រមមេត្តាពិនិត្យពិចារណា ជាពិសេសអង្គហេតុ ៦០.០០០$ ជាអង្គហេតុពិតប្រាកដ ព្រោះគាត់ហ៊ានដាក់ធូបមកស្បថជូន ទោះជាកូនក្ដីរបស់ខ្ញុំគ្មានឯកសារមកបង្ហាញ ក៏បង្ហាញឆន្ទៈជូនតុលាការ ។ សំណូមពរ សុំអោយតុលាការច្រានចោលពាក្យបណ្ដឹងរបស់ដើមចោទចោលជាអាសារបង់ ។ គប្បីតុលាការពិនិត្យពិចារណា ផ្អែកតាមភស្តុតាង និងសម្រេចតាមច្បាប់ ។

១០-តាមកិច្ចសន្យាចងការប្រាក់ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ធ្វើឡើងរវាងសហចុងចម្លើយឈ្មោះ [redacted] ម៉ារ៉ាន់ ភេទស្រីអាយុ៣៩ឆ្នាំ និងម្ដាយឈ្មោះ[redacted] រុន ជាមួយសហដើមចោទឈ្មោះ[redacted] តិចម៉េង ភេទប្រុសអាយុ៥០ឆ្នាំនិងប្រពន្ធឈ្មោះ[redacted]គីមចាយ អាយុ៤៨ឆ្នាំ ដោយបញ្ជាក់ថាឈ្មោះ[redacted]ម៉ារ៉ាន់ និងម្ដាយឈ្មោះ[redacted] រុន បានចងការប្រាក់ចំនួន៤២.២០០$ ដោយបង់ការប្រាក់ចំនួន១.២៦៦$ ក្នុងមួយខែ ប្រាកដមែន ។

១១-តាមកំណត់ត្រាដៃចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ឈ្មោះ[redacted]ាន់ ឃើញថាឈ្មោះរ៉ាន់ និងឈ្មោះរុន បានចងការប្រាក់ចំនួន៤២.២០០$ សងរួចមួយចំនួននៅខ្វះចំនួន២៩.២២៨$ ប្រាកដមែន ។

១២-តាមកំណត់ហេតុចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ របស់គណកម្មការដោះស្រាយទំនាស់ថ្នាក់ឃុំខ្វាវ បញ្ជាក់ថា ពេលដោះស្រាយគ្នាលោកស្រី[redacted]គីមចាយ មានមតិថាឈ្មោះ[redacted] ម៉ារ៉ា ចំនួនៈ៧៧.៨៦០$ និងឈ្មោះ[redacted]ម៉ារ៉ាន់ ចំនួនៈ២៩.២០០$ ប៉ុន្តែម្ចាស់បំណុលថា[redacted] ម៉ារ៉ា ចំនួនៈ៥៣.០០០$ ទេ [redacted]ម៉ារ៉ាន់ នៅសល់តែ៧.០០០$ ទេ។ចំពោះឈ្មោះ[redacted]ម៉ារ៉ា ម្ចាស់លុយថា៧៧.៨៦០$ តែ[redacted]ម៉ារ៉ា ថានៅជំពាក់៥៣.០០០$ ទេ តែបានសងរួចរាល់ហើយ ។ ឈ្មោះ[redacted]ម៉ារ៉ាន់ ម្ចាស់លុយថាៈ២៩.២០០$ តែ[redacted]ម៉ារ៉ាន់ ថា ៧.០០០$ (តែអត់មានអីសងបន្ត) ។ ប៉ុន្តែលោកស្រីអៀ គីមចាយ ថាមិនបានសងប្រាក់៥៣.០០០$ នោះទេ ។

១៣-តាមចម្លើយសហដើមចោទ សហចុងចម្លើយ មេធាវី និងសាក្សី ព្រមទាំងភស្តុតាងនានា បញ្ជាក់បានថា កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ សហចុងចម្លើយឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] រុន បានទៅចងការប្រាក់ពីដើមចោទចំនួន៤២.២០០$ ដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ។ ក្រោយមកឈ្មោះ[redacted] ម៉ារ៉ាន់ និងឈ្មោះ[redacted] រុន សងបានចំនួន១៣.០០០$ នៅខ្វះចំនួន២៩.២០០$ទៀតពុំព្រមសងក៏បានទៅដោះស្រាយគ្នានៅសាលាឃុំខ្វាវ ចំនួន០២លើក លើកទី១នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចុងម្លើយទទួលស្គាល់នៅជំពាក់ប្រាក់ដើមចោទចំនួន២៩.២០០$ លើកទី២នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ចុងចម្លើយឆ្លើយថានៅជំពាក់ដើមចោទចំនួន៧.០០០$ លុះមកដល់តុលាការសហចុងចម្លើយឆ្លើយថា ពុំមាននៅជំពាក់ប្រាក់ដើមចោទទៀតទេ ។ ចំណែកសហដើមចោទបានឆ្លើយថាសហចុងចម្លើយនៅជំពាក់ប្រាក់ខ្លួនចំនួន២៩.២០០$ ពុំដែលបានសងទេ ។ ការលើកឡើងរបស់គូភាគី សុទ្ធតែមានអំណាស់អំណាងរៀង១ខ្លួន ។ តុលាការគប្បីពិនិត្យពិចារណានិងសម្រេចដោយផ្អែកតាមភស្តុតាងដែលបានដាក់ជូនតុលាការ ។

១៤-សហដើមចោទទាមទារប្រាក់ដើមចំនួន២៩.២០០$ និងសុំអនុវត្តសាលក្រមជាបណ្ដោះអាសន្នលើចំណុចនេះ ។ ដូច្នេះតុលាការគប្បីប្រកាសអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើម ស្របតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

១៥-សហដើមចោទ ទាមទារការប្រាក់១៨% ក្នុង១ឆ្នាំ លើកប្រាក់ដើមចំនួន២៥.២០០$ គិតចាប់ពីថ្ងៃចុះកិច្ចសន្យា ថ្ងៃទី១១ខែមករា ឆ្នាំ២០២១ នៅក្នុងកិច្ចសន្យាចងការប្រាក់ គិតការប្រាក់ក្នុង១ខែ ។ ប៉ុន្តែបើពិនិត្យទៅលើភស្តុតាង និងសាក្សី បញ្ជាក់ថាសហចុងចម្លើយទទួលស្គាល់ថា នៅជំពាក់ប្រាក់សហដើមចោទនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ គប្បីតុលាការ សម្រេចអោយការប្រាក់ដោយចាប់គិតពីថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ២០២១ វិញ។

១៦-សហដើមចោទ បានទាមទារសំណងជំងឺចិត្ត ការខាតបង់ពេលវេលាផលប្រយោជន៍និងថ្លៃចំណាយសេវាផ្លូវច្បាប់ចំនួន២០.០០០$។ ដោយសហចុងចម្លើយមានជីវភាពក្រីក្រ គប្បីតុលាការមិនសម្រេចអោយឡើយ។

១៧-ដើមចោទបានស្នើសុំឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។ គប្បីតុលាការពិចារណា លើមាត្រា ៦៤ កឋាខណ្ឌ១ ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលស្គាល់ពាក្យបណ្តឹងចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣របស់សហដើមចោទឈ្មោះ [redacted] តិចម៉េង និងប្រពន្ធឈ្មោះ [redacted] តឹមចាយ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ារ៉ាន់ និងឈ្មោះ [redacted] រុន សងប្រាក់ដើមចំនួន ២៥.២០០$(ពីរម៉ឺនប្រាំបួនពាន់ពីររយ)ដុល្លារអាមេរិក ទៅសហដើមចោទឈ្មោះ [redacted] តិចម៉េង និងប្រពន្ធឈ្មោះ [redacted] តឹមចាយ ។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ារ៉ាន់ និងឈ្មោះ [redacted] រុន បង់ការប្រាក់ចំនួន១២% ក្នុង១ឆ្នាំ លើប្រាក់ដើមចំនួន២៥.២០០$ គិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់សងគ្រប់ចំនួន ទៅសហដើមចោទឈ្មោះ [redacted] តិចម៉េង និងប្រពន្ធឈ្មោះ [redacted] តឹមចាយ ។

៤-សាលក្រមនេះមានប្រសិទ្ធិភាពអនុវត្តបណ្តោះអាសន្ន ចំពោះប្រាក់ដើមចំណុចទី២ នៃសេចក្តីសម្រេចខាងលើ ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

ថ្ងៃពុធ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

| | |
|---|---|
| **ក្រឡាបញ្ជី** | **ចៅក្រម** |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

| | |
|---|---|
| បានឃើញ<br>**ចៅក្រម** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner